រាជធានីភ្នំពេញ៖ ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៥ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីជំនួបពិភាក្សាការងារ រវាងអគ្គនាយកដ្ឋានពន្ធដារ និងសហព័ន្ធ ស្រូវ អង្ករ កម្ពុជា

ឆ្លើយតបទៅនឹងសំណើសុំរបស់តំណាងសហព័ន្ធស្រូវ-អង្ករ កម្ពុជា ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារមួយចំនួន បានអនុញ្ញាតឲ្យសមាជិកសហព័ន្ធស្រូវ-អង្ករ កម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នាវេលាម៉ោង ៩:០០ ព្រឹក ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ។



ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះគណៈប្រតិភូនៃសហព័ន្ធស្រូវ-អង្ករ កម្ពុជា ដែលបានជួបសម្តែងការគួរសម និងពិភាក្សាការងារនាព្រឹកនេះ។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានគូសបញ្ជាក់ជម្រាបជូនគណៈប្រតិភូសហព័ន្ធស្រូវ-អង្ករ កម្ពុជា អំពីសារៈសំខាន់នៃវិស័យកសិកម្ម ដោយហេតុថា ប្រជាពលរដ្ឋកម្ពុជា ប្រមាណជា៨៥% គឺជាកសិករដែលប្រកបរបរកសិកម្មដាំដុះផលិតផលកសិកម្ម ជាពិសេស គឺដំណាំស្រូវ។ ផ្អែកលើកត្តានេះ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានជំរុញ និងលើកកម្ពស់វិស័យកសិកម្មនេះ តាមរយៈការផ្តល់ការលើកទឹកចិត្តពន្ធដារដូចដែលបានអនុវត្តកន្លងមក ក្នុង

ន័យជួយសម្រួលដល់ធុរជនដែលប្រកបធុរកិច្ចលើវិស័យស្រូវ-អង្ករ និងជាពិសេស គឺក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ របស់ប្រជាកសិករកម្ពុជា។

ឯកឧត្តម **សុខ ពុទ្ធិវុធ** ប្រធានសហព័ន្ធស្រូវ-អង្ករ កម្ពុជា បានសម្តែងនូវសមានចិត្តអំណរគុណចំពោះឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ ដែលបានចំណាយពេលវេលាដ៏មានតម្លៃនិងមមាញឹកពីការងារ អនុញ្ញាតឱ្យតំណាងសមាជិកសហព័ន្ធចូលជួបសម្តែងការគួរសម ពិភាក្សាការងារនាឱកាសនេះ។ ឯកឧត្តមប្រធានសហព័ន្ធ ក៏បានជម្រាបរាយការណ៍ជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលផងដែរ អំពីស្ថានភាពទូទៅ និងបញ្ហាប្រឈមនានា ដែលសហព័ន្ធបាននិងកំពុងជួបប្រទះ។ ឯកឧត្តមប្រធានសហព័ន្ធបានសង្កត់ធ្ងន់ថា ថ្វីដ្បិតតែមានការលើកទឹកចិត្តពន្ធដារលើវិស័យកសិកម្ម ពីសំណាក់រាជរដ្ឋាភិបាល ក៏ដូចជាពីសំណាក់អគ្គនាយកដ្ឋានពន្ធដារក៏ដោយ ក៏តម្លៃស្រូវ-អង្កររបស់ព្រះរាជាណាចក្រកម្ពុជាហាក់មានតម្លៃខ្ពស់ជាងគេ ដែលនេះគឺអាចបណ្តាលមកពីកង្វះខាតបច្ចេកវិទ្យាក្នុងការផលិត និងមួយចំណែកណានោះពាក់ព័ន្ធនឹងកាតព្វកិច្ចសារពើពន្ធ ដែលនាំទៅដល់ការកើនឡើងខ្ពស់នូវថ្លៃដើម។ ជាងនេះទៅទៀត តំណាងសហព័ន្ធក៏បានសម្តែងនូវកង្វល់មួយចំនួន ដែលអាចជះឥទ្ធិពលអវិជ្ជមានដល់កំណើននៃការជំរុញការនាំចេញស្រូវ-អង្ករកម្ពុជា។

ឆ្លើយតបនឹងកង្វល់ទាំងអម្បាលម៉ានរបស់តំណាងសហព័ន្ធ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនថា អគ្គនាយកដ្ឋានពន្ធដារស្វាគមន៍រាល់ការផ្តល់ជូនធុរជនគ្រប់មជ្ឈដ្ឋាន នូវព័ត៌មាននានាពាក់ព័ន្ធនឹងវិស័យពន្ធដារ។ អគ្គនាយកដ្ឋានតែងតែដាក់នៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋាន នូវព័ត៌មានចម្រុះ និងថ្មីៗដែលបានកែសម្រួល ទាក់ទងនឹងច្បាប់ ក៏ដូចជាបទប្បញ្ញត្តិស្តីពីពន្ធដារ ជូនអ្នកជាប់ពន្ធដើម្បីស្វែងយល់។ ជាងនេះទៅទៀត អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងកែសម្រួលនីតិវិធីពន្ធដារជូនអ្នកជាប់ពន្ធគ្រប់មជ្ឈដ្ឋាន តាមរយៈការធ្វើទំនើបកម្មវិស័យពន្ធដារ ជាពិសេស ការសម្រួលដល់ដំណើរការចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិក (E-Registration) ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធ ប្រកបដោយតម្លាភាព និងគណនេយ្យភាព ព្រមទាំងឆ្លើយតប និងតាមទាន់សភាពការណ៍នៃបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។ ដោយឡែកចំពោះសំណូមពរផ្សេងៗទៀត ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលយកទៅពិនិត្យ ពិភាក្សា និងដាក់ជូនថ្នាក់ដឹកនាំក្រសួងដើម្បីពិនិត្យ និងសម្រេច ព្រោះថា អគ្គនាយកដ្ឋានពន្ធដារគឺជាស្ថាប័នក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធ្វើការតាមឋានានុក្រម ប្រកបដោយវិជ្ជាជីវៈខ្ពស់។

ក្នុងជំនួបពិភាក្សានេះដែរ តំណាងសហព័ន្ធស្រូវ-អង្ករ កម្ពុជា បានសម្តែងនូវការកោតសរសើរចំពោះវឌ្ឍនាការរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមការដឹកនាំគ្រប់គ្រងរបស់ឯកឧត្តម **គន់ ទិមុល** ប្រតិភូរាជរដ្ឋាភិបាល ជាពិសេស គោលនយោបាយកែទម្រង់ និងការធ្វើទំនើបកម្មវិស័យពន្ធដារកម្ពុជា ដែលកំពុងតែទទួលបានលទ្ធផលផ្លែផ្កាជាវិជ្ជមាន ជាបន្តបន្ទាប់ និងឥតឈប់ឈរ។ សហព័ន្ធស្រូវ-អង្ករ កម្ពុជា សន្យានឹងផ្តល់ និងបន្តកិច្ចគាំទ្រចំពោះឆន្ទៈដ៏មោះមុតលើវិថីនៃការកែទម្រង់វិស័យពន្ធដាររបស់យើង។



ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានសម្តែងនូវសេចក្តីអរគុណចំពោះការចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ធុរជនដែលប្រកបរបរធុរកិច្ចក្នុងវិស័យស្រូវ-អង្ករ និងទទួចស្នើឱ្យធុរជនទាំងអស់ បន្តការផ្តល់កិច្ចសហការល្អជាមួយរដ្ឋបាលសារពើពន្ធ សំដៅអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកាតព្វកិច្ចសារពើពន្ធ ស្របតាមច្បាប់កំណត់។

ជំនួបពិភាក្សាការងារនេះ បានបញ្ចប់នៅវេលាម៉ោង ១១ និង៥០ នាទីព្រឹក នាថ្ងៃ ខែ ឆ្នាំដដែល ក្នុងបរិយាកាសស្និទ្ធស្នាល និងសហប្រតិបត្តិការខ្ពស់៕